PESTECH

# សេចក្តីជូនដំណឹង
# ស្តីពី
# ការស្នើសុំពន្យារពេលក្នុងការចេញផ្សាយរបាយការណ៍ប្រចាំត្រីមាសទី៣ សម្រាប់ត្រីមាសដែលបានបញ្ចប់នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ របស់ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក

ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក ("ផថខ") មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិក វិនិយោគិន និងសាធារណជនឲ្យបានជ្រាបថា និយ័តករមូលបត្រកម្ពុជា បានអនុម័តលើពាក្យស្នើសុំរបស់ ផថខ ក្នុងការពន្យារពេលចេញផ្សាយរបាយការណ៍ប្រចាំត្រីមាសទី៣ សម្រាប់ត្រីមាសដែលបានបញ្ចប់នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ (របាយការណ៍ប្រចាំត្រីមាសទី៣) របស់ ផថខ ដែលនឹងត្រូវពន្យារពេលក្នុងការចេញផ្សាយរហូតដល់ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០២៣ វិញ។

ដោយហេតុមានការឈប់សម្រាកក្នុងឱកាសបុណ្យជាតិនានាក្នុងអំឡុងខែមេសា និង ខែឧសភា ឆ្នាំ២០២៣ ការស្នើសុំពន្យារពេលនេះ នឹងអនុញ្ញាតឲ្យ ផថខ និង សវនកររបស់យើង ក្រុមហ៊ុន ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត មានពេលវេលាបន្ថែមក្នុងការពិនិត្យឡើងវិញ និងបញ្ចប់របាយការណ៍ប្រចាំត្រីមាសទី៣។

ដោយហេតុនេះ ផថខ នឹងចេញផ្សាយរបាយការណ៍ប្រចាំត្រីមាសទី៣ នៅឬមុន ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០២៣។

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣

**ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក**

ព្រះរាជាណាចក្រកម្ពុជា
ផេសថិក
(ខេមបូឌា) ម.ក
PESTECH (CAMBODIA)
PLC
KINGDOM OF CAMBODIA

ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក (លេខចុះបញ្ជី៖ ០០០០០៩៥៧)

(ក្រុមហ៊ុន PESTECH)

អគារលេខ ៣៥ ជាន់ទី១០ មហាវិថីម៉ៅសេទុង ភូមិ០៩ សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ៖ +៨៥៥ ២៣ ៨៨២ ១០៥ ទូរសារ +៨៥៥ ២៣ ៨៨២ ១០៦ គេហទំព័រ៖ www.pestech-international.com